ថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០៨

# នគរបាលដែលគេឃុំខ្លួនត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យដោយសារសុខភាពចុះខ្សោយ

លោក **ព្រីង ពៅ** ជានគរបាលក្រុងកែប ដែលក្រសួងមហាផ្ទៃបានឃុំខ្លួនដោយមិនស្របច្បាប់ជាងមួយខែមកហើយ ត្រូវបាននគរបាលបញ្ជូនទៅកាន់មន្ទីរពេទ្យព្រះមុនីវង្សកាលពីម្សិលមិញ ។ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) និងអង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (លីកាដូ) មានការព្រួយបារម្ភជាខ្លាំងអំពីសុខភាពរបស់គាត់ និងជាថ្មីម្តងទៀត យើងសូមអំពាវនាវអោយមានការដោះលែងលោកព្រីង ពៅ អោយបានឆាប់តាមដែលអាចធ្វើទៅបាន ។

លោក ព្រីង ពៅ ជាមន្ត្រីនគរបាលស្រុកម្នាក់នៃសាលាក្រុងកែប ត្រូវបានចាប់ខ្លួនដោយគ្មានដីកាតុលាការកាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ បន្ទាប់មក នគរបាលផ្នែកអនុវត្តបទបញ្ជាបានឃុំរូបលោកក្នុងបន្ទប់មួយនៃអាគារក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ ។ លោកបានទទួលការវាយដំ និងឃុំឃាំងដោយជាប់ខ្នោះ យ៉ាងតិចណាស់អស់មួយរយៈពេលដែរ នេះបើយោងតាមព័ត៌មានគួរអោយជឿបានដែលអាដហុកនិងលីកាដូទទួលបាន ។

មន្ត្រីក្រសួងមហាផ្ទៃបានបញ្ជាក់ថា លោក ព្រីង ពៅ កំពុងជាប់ឃុំក្រោមបទបញ្ជារបស់ឧត្តមសេនីយ៍ អគ្គនាយកនគរបាលជាតិ ហុក ឡងឌី ។ មន្ត្រីទាំងនោះមានប្រសាសន៍ថា លោក ព្រីង ពៅ ត្រូវបានគេឃុំឃាំងដើម្បីអប់រំវិន័យឡើងវិញ ដោយសារតែគាត់មិនគោរពបញ្ជាថ្នាក់លើ អំពីរឿងជំលោះដីធ្លីនៅក្រុងកែប ដែលជាប់ពាក់ព័ន្ធជាមួយម្ចាស់ក្សត្រីម៉ារី រណឫទ្ធិ ។ ទោះជាយ៉ាងនេះក្តី តុលាការខេត្តបានប្រាប់អ្នកស៊ើបអង្កេតសិទ្ធិមនុស្ស ថា ខ្លួនមិនបានទទួលពាក្យបណ្តឹងណាមួយប្តឹងពីលោកព្រីង ពៅ ហើយក៏មិនបានចោទប្រកាន់គាត់ពីបទអ្វីមួយនៅឡើយដែរ ។

លោកនី ចរិយា អ្នកសំរបសំរួលផ្នែកស៊ើបអង្កេតពីសមាគមអាដហុកមានប្រសាស៍ថា "ច្បាប់កម្ពុជាបញ្ជាក់ថា គ្មានជនណាម្នាក់អាចត្រូវឃុំឃាំងក្នុងកន្លែងឃុំឃាំងលើស ៤៨ម៉ោង ដោយគ្មានការចោទប្រកាន់ឡើយ " ដោយមិនបានគិតដល់រឿងជំលោះដីធ្លី និងមិនបានពិចារណាថា អ្នកណាជាម្ចាស់ដីពិតប្រាកដនោះផង លោក ព្រីង ពៅ បានក្លាយជាជនរងគ្រោះដែលត្រូវបានឃុំខ្លួនដោយមិនស្របច្បាប់ និងបានទទួលនូវការប្រព្រឹត្តអមនុស្សធម៌ពីសំណាក់នគរបាលរួចទៅហើយ ។

ថ្ងៃទី២៤ ខែមិនា ម្សិលមិញ លោក ព្រីង ពៅ ត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យព្រះមុនីវង្ស ដើម្បីពិនិត្យសុខភាពក្រោមកិច្ចការពារសុវត្ថិភាពដោយមន្រ្តីនគរបាល១០នាក់ ។ គេរាយការណ៍មកថា ស្ថានភាពសុខភាពរបស់លោក ព្រីង ពៅ មិនមានការប្រែប្រួលទេ គាត់មានបញ្ហាផ្នែកផ្លូវដង្ហើម និងមានការពិបាកដើរដោយសារតែការឃុំឃាំងមានរយៈពេលយូរ ។ កន្លងមក គ្រូពេទ្យពីអង្គការមិនមែនរដ្ឋាភិបាលត្រូវបានបដិសេធជាលក្ខណៈប្រព័ន្ធតាមបញ្ជារបស់មេបញ្ជាការនគរបាលផ្នែកអនុវត្តបទបញ្ជា មិនអោយចូលជួបជនរងគ្រោះឡើយ ។

កញ្ញា ណាលី ពីឡូក នាយិកាអង្គការលីកាដូមានប្រសាសន៍ថា"ការបញ្ជូនលោក ព្រីង ពៅ ទៅកាន់មន្ទីរពេទ្យដែលគេមិនបានរំពឹងទុកជាមុន បន្ទាប់ពីការឃុំខ្លួនជាច្រើនសប្តាហ៍មក និងការសង្ស័យអំពីការធ្វើទារុណកម្មលើរូបលោក គឺជាការគួរអោយព្រួយបារម្ភ" ណាលី បានបន្តទៀតថា " លោក ព្រីង ពៅ គួរតែត្រូវបានដោះលែងពីកន្លែងឃុំឃាំងរបស់នគរបាលជាបន្ទាន់ ដើម្បីអោយគាត់បានទទួលការព្យាបាលពេញលេញ និងត្រឹមត្រូវ ។

អង្គការលីកាដូ និងសមាគមអាដហុក សូមស្នើអោយមានការដោះលែងលោក ព្រីង ពៅ អោយបានឆាប់។ម្យ៉ាងទៀត សូមស្នើអោយមានការស៊ើបអង្កេតឯករាជ្យមួយចំពោះករណីឃុំឃាំងដោយមិនស្របតាមច្បាប់នេះដែលបានឈានចូលដល់សប្តាហ៍ទី៦ ហើយ ។

ព័ត៌មានបន្ថែម សូមទំនាក់ទំនង
កញ្ញា ណាលី ពីឡូក នាយិកាអង្គការលីកាដូ ០១២ ៨០៣ ៦៥០
លោក នី ចរិយា អ្នកសំរបសំរួលផ្នែកស៊ើបអង្កេតពីសមាគមអាដហុក ០១១ ២៧៤ ៩៥៩